**<u>វេទិកា</u>**

**<u>ស្ដីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល</u>**

**<u>ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ នៅអគារនៃក្រសួងមហាផ្ទៃ</u>**

របាយការណ៍របស់លោក **សឿង សារឿន** នាយកប្រតិបត្តិអង្គការ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងតំណាងអង្គការសង្គមស៊ីវិលមួយចំនួន

---

**សូមគោរព! សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា បង ប្អូន ជាភ្ញៀវជាតិ និងអន្តរជាតិ និង អង្គវេទិកាទាំងមូល!**

ក្នុងនាមគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលមានអង្គការជាតិ និងអន្តរជាតិ ជិត ២០០ ជាសមាជិក ដែលកំពុងប្រតិបត្តិការងារគ្រប់វិស័យលើផ្ទៃប្រទេស និងក្នុងនាមអង្គការសង្គមស៊ីវិលពាក់ព័ន្ធមួយចំនួនទៀត ខ្ញុំសូមសម្ដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងមហាផ្ទៃ ដែលបានរៀបចំ និងអនុញ្ញាតិឲ្យខ្ញុំបាទ និងសហសេវិកពីសង្គមស៊ីវិលបានចូលរួមក្នុង ***<u>វេទិកាស្ដីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល</u>*** នាថ្ងៃនេះ។ ខ្ញុំបាទសូមជម្រាបជូនថា អង្គការ CCC ជាអង្គការសមាជិកភាពដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា ហើយដែលមានបេសកកម្មក្នុងការធ្វើការងារជាដៃគូដើម្បីការលើកកម្ពស់អភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ នៅក្នុងឱកាសនៃវេទិកាដ៏ថ្លៃថ្លានេះ ខ្ញុំបាទ សូមអនុញ្ញាតិធ្វើរបាយការណ៍ស្ដីអំពីស្ថានភាពទូទៅនិងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ក្រោយពីវេទិកាទី១ កាលពីខែមិថុនា ឆ្នាំ២០១៨ ដែលមានដូចតទៅ:

## សមិទ្ធិផលសំខាន់ៗក្នុងភាពជាដៃគូរវាង រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងឆ្នាំ២០១៨៖

១. តាមសេចក្ដីសម្រេចលេខ ៨៤ សសរ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយសំណើនិងសំណូមពររបស់អង្គការសង្គមស៊ីវិល ដែលក្នុងនោះមានសមាសភាពមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលចំនួនប្រាំបីរូប មកពីក្រសួងនានាចំនួនបួន ត្រូវបានតែងតាំង

ដើម្បីទទួលបន្ទុកការងារនេះ។ ក្រុមការងារនេះ ត្រូវបំពេញការងាររបស់ខ្លួនក្រោមការណែនាំ និងដឹកនាំផ្ទាល់ពីសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

២. សារាចរលេខ ០៦ សរ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលស្តីអំពីការរៀបចំឲ្យមានការពិគ្រោះយោបល់ក្នុងដំណើរការតាក់តែងក្របខណ្ឌគោលនយោបាយ និងច្បាប់នានា ដែលនៅក្នុងនោះ រាជរដ្ឋាភិបាលបានណែនាំដល់ក្រសួង ស្ថាប័នសាម ត្រូវរៀបចំឲ្យមានការពិគ្រោះយោបល់ ឲ្យបានទូលំទូលាយតាមការចាំបាច់ដោយមានការចូលរួមពីតំណាងអ្នកជាប់ពាក់ព័ន្ធទាំងអស់ រួមទាំងអង្គការសង្គមស៊ីវិលផងដែរ។

៣. វេទិកាទៀងទាត់ស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលវេទិកាលើកទីមួយត្រូវបានរៀបចំឡើងនៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ដែលក្នុងនោះអនុសាសន៍មួយចំនួនដែលបានលើកឡើងដោយអង្គការសង្គមស៊ីវិល ត្រូវបានទទួលយកនិងដោះស្រាយដោយរាជរដ្ឋាភិបាល មានជាអាទិ៍ ការបង្កើតក្រុមការងារចម្រុះអន្តរក្រសួងដើម្បីដោះស្រាយបញ្ហាប្រឈមរបស់អង្គការសង្គមស៊ីវិល ការចេញនូវសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃអំពីការធ្វើសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនតម្រូវឲ្យមានការជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន ក្នុងរយៈពេលបីថ្ងៃមុនពេលចាប់ផ្តើមធ្វើសកម្មភាព ជាដើម។

៤. រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បានបន្តភាពជាដៃគូប្រកបដោយប្រសិទ្ធភាពនៅក្នុងវិស័យមួយចំនួន ដូចជាវិស័យអប់រំ វិស័យសុខាភិបាល វិស័យកសិកម្ម វិស័យអភិវឌ្ឍជនបទ និងរួមទាំងការលើកកម្ពស់ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF) សំដៅធ្វើឲ្យការផ្តល់សេវានៅថ្នាក់ក្រោមជាតិ ប្រកបទៅដោយគុណភាព តម្លាភាព គណនេយ្យភាព និងការបំពេញឲ្យគ្នាទៅវិញទៅមក រវាងអ្នកជាប់ពាក់ព័ន្ធទាំងអស់។

៥. រាជរដ្ឋាភិបាលតាមរយៈក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលបានធ្វើការក្នុងភាពជាដៃគូ និងយោគយល់គ្នាដើម្បីដោះស្រាយបញ្ហាមួយចំនួន ពាក់ព័ន្ធនឹងបរិយាកាសបំពេញការងាររបស់អង្គការសង្គមស៊ីវិល។ មានយន្តការដ៏គួរឲ្យចាប់អារម្មណ៍មួយចំនួនដូចជា ការបង្កើតក្រុមការងាររួមគ្នារវាងអគ្គនាយកដ្ឋានពន្ធដារ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់សារពើពន្ធ យន្តការ សន្ទនាស្តីពីច្បាប់ការងារ យន្តការសន្ទនាស្តីពីច្បាប់គណនេយ្យនិងសវនកម្ម យន្តការភាពជាដៃគូពាក់ព័ន្ធទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា យន្តការដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍជាដើម។

៦. ក្រសួងមហាផ្ទៃ និងអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា បានពិភាក្សា និងឯកភាពព្រមទាំងបានចុះអនុស្សរណៈនៃយោគយល់ស្តីពីការធ្វើជំរឿនអង្គការ សមាគមមិនមែនរដ្ឋាភិបាល និងការសិក្សាអំពីការចូលរួមវិភាគទានដើម្បីការអភិវឌ្ឍសង្គមកម្ពុជា ដែលអនុវត្តចាប់ពី តុលា ឆ្នាំ២០១៨ ដល់ ខែតុលាឆ្នាំ២០១៩។

**បញ្ហាប្រឈម៖**

១. បើទោះបីរាជរដ្ឋាភិបាលបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ក្រុមការងារនេះមិនទាន់មានតំណាងមកពីអង្គការសង្គមស៊ីវិលនៅឡើយ។ អវត្តមានសមាសភាពតំណាងរបស់អង្គការសង្គមស៊ីវិលនៅក្នុងយន្តការនេះ អាចប៉ះពាល់ទៅដល់គុណភាពនៃការទទួល និងប្រមូលព័ត៌មាន និងការធ្វើសេចក្តីសម្រេចចិត្តទាំងឡាយដែលមានការចូលរួមប្រកបដោយអត្ថន័យ ដែលពាក់ព័ន្ធនឹងបញ្ហាប្រឈមរបស់អង្គការសង្គមស៊ីវិល។

២. បើទោះបីរាជរដ្ឋាភិបាលបានបញ្ជាក់នៅក្នុងវេទិកាលើកទី១ស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល អំពីការមិនដែលចោទប្រកាន់សមាគម និងអង្គការណាមួយជាផ្នែកនៃគណបក្សប្រឆាំង និងបដិវត្តពណ៌ក៏ដោយ ក៏ប៉ុន្តែសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន នៅតែត្រូវបានគេរើសអើងនិងនៅមិនទាន់ទទួលបានកិច្ចសហការពេញលេញពីអាជ្ញាធរពាក់ព័ន្ធនៅឡើយ ពិសេសនៅថ្នាក់ក្រោមជាតិ។

៣. អាជ្ញាធរខេត្តមួយចំនួន នៅមិនទាន់ទទួលស្គាល់បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្តនៅឡើយ ហើយតម្រូវឲ្យបណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្តចុះអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងមហាផ្ទៃ និងបំពេញនូវតម្រូវការផ្សេងៗទៀតទៅតាមការទាមទាររបស់ខ្លួន។

៤. អាជ្ញាធរខេត្តមួយចំនួនមិនបានគោរពពេញលេញតាមសេចក្តីណែនាំ សេចក្តីជូនដំណឹង ឬលិខិតបទដ្ឋានគតិយុត្តិនានាដែលចេញដោយក្រសួងមហាផ្ទៃឡើយ ដោយពេលខ្លះមានការអនុវត្តផ្ទុយពីអ្វីដែលក្រសួងមហាផ្ទៃបានណែនាំ ឬជូនដំណឹងទៅទៀត។ អាជ្ញាធរមូលដ្ឋានខ្លះ មិនអនុញ្ញាត្តិ ឬបង្កការរំខាន និងបានបិទនូវសិទ្ធិសេរីភាពជាមូលដ្ឋាន និងបិទនូវសកម្មភាពមួយចំនួនរបស់អង្គការ សង្គមស៊ីវិល ឬរបស់បណ្តាញអង្គការសង្គមស៊ីវិល ដោយប្រើប្រាស់ហេតុផលផ្ទាល់ខ្លួន និងមិនមានការបកស្រាយតាមផ្លូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលកំពុងមានជាធរមាន។ អាជ្ញាធរមូលដ្ឋានខ្លះ តម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលផ្តល់ជូនរបាយការណ៍សកម្មភាពលើសពីការតម្រូវដោយច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

៥. ការយល់គ្នា និងការគាំទ្រគ្នាទៅវិញទៅមករវាងអង្គការសង្គមស៊ីវិល និងអាជ្ញាធរថ្នាក់ខេត្ត នៅមានកម្រិតទាបនៅឡើយ។ នៅក្នុងឆ្នាំ ២០១៨ អង្គការសង្គមស៊ីវិល និងបណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្តនៅមានការលំបាកក្នុងការស្វែងរកការគាំទ្រ និងចូលរួមពីសំណាក់អាជ្ញាធរថ្នាក់ក្រោមជាតិ នៅក្នុងសកម្មភាពពាក់ព័ន្ធសំខាន់ៗរបស់ខ្លួន។ ទន្ទឹមនឹងនោះ អង្គការសង្គមស៊ីវិលក៏បានសង្កេតឃើញថា សកម្មភាពការងាររបស់អាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលនៅមិនសូវមានភាពស៊ីសង្វាក់គ្នានៅឡើយ (ខុសសកម្មភាព ខុសតំបន់គោលដៅ ខុសវិស័យអាទិភាព)។

៦. យន្តការ និងសមត្ថភាពក្នុងការអនុវត្ត និងផ្សព្វផ្សាយ អប់រំ អំពីច្បាប់ថ្មីៗ និងបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលដែលដាក់ចេញដោយរាជរដ្ឋាភិបាលបានបង្កជាឧបសគ្គដល់ដំណើរការរបស់សង្គមស៊ីវិល និងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងនោះមានដូចជាៈ ប្រព័ន្ធនៃការដាក់បញ្ជូនរបាយការណ៍ ទម្រង់របាយការណ៍ សង្កត់ភាពក្នុងការបកស្រាយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងសមភាពក្នុងការអនុវត្តច្បាប់។ ទន្ទឹមនឹងនេះ ក៏មានការដាក់ចេញនូវច្បាប់ គោលនយោបាយ និងយន្តការថ្មីៗមួយចំនួនធំ ដែលការណ៍នេះ តម្រូវឲ្យសង្គមស៊ីវិលរត់តាមឲ្យទាន់នូវការយល់ដឹង និងអនុវត្តតាមច្បាប់ និងគោលនយោបាយថ្មីៗទាំងនោះ។

៧. ការរីកចំរើនផ្នែកសេដ្ឋកិច្ច គួបផ្សំនឹងនិន្នាការនយោបាយ និងការអភិវឌ្ឍរបស់ប្រទេស ព្រមទាំងនិន្នាការរបស់ដៃគូអភិវឌ្ឍផងដែរ បានធ្វើឲ្យប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់អង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលមួយភាគធំ បានទទួលរងនូវផលប៉ះពាល់នេះ ដោយសារខ្លួនមិនទាន់មានសមត្ថភាពក្នុងការធ្វើពិពិធកម្មប្រភពចំណូល ឬថា ពួកគេមានសមត្ថភាពក្នុងការធ្វើពិពិធកម្មរកប្រាក់ចំណូលសម្រាប់បុព្វហេតុសកម្មភាពមនុស្សធម៌ដោយខ្លួនហើយ ប៉ុន្តែជួបឧបសគ្គ ដោយត្រូវគោរពកាតព្វកិច្ចសារពើពន្ធនានា ដូចដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធដូចវិស័យឯកជនដែរ និងម្យ៉ាងវិញទៀតដោយសារខ្លួនឯងមិនទាន់ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រភពខាងក្នុងនៅឡើយ ដូចជាពីសំណាក់វិស័យឯកជន ពីរាជរដ្ឋាភិបាល និងពីសប្បុរសជនជាដើម។

**សំណូមពរៈ**

យើងខ្ញុំសូមស្នើដល់រាជរដ្ឋាភិបាល នូវសំណូមពរដ៏សំខាន់មួយចំនួនដូចតទៅ ៖

១. ស្នើសុំរាជរដ្ឋាភិបាលបញ្ចូលសមាសភាពជាតំណាងពីអង្គការសង្គមស៊ីវិល ទៅក្នុងក្រុមការងារបច្ចេកទេសដោះស្រាយសំណើនិងសំណូមពររបស់អង្គការសង្គមស៊ីវិល។ ក្រុមការងារនេះគួរដើរតួនាទីដើម្បីពិភាក្សា និងរកដំណោះស្រាយល្អបំផុតចំពោះបញ្ហាពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល និងរួមទាំងច្បាប់ស្តីពីសហជីពផងដែរ។ ក្រុមការងារនេះគួរដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំវេទិកាភាពជាដៃគូនេះ**យ៉ាងតិចពីរ (២)ដងក្នុងមួយ (១)ឆ្នាំ ទាំងក្នុងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ឲ្យដំណើរការទៅយ៉ាងរលូន។ វេទិកាភាពជាដៃគូតាមវិស័យគួរត្រូវរៀបចំឡើងជាទៀងទាត់ និងមានការចូលរួមប្រកបដោយអត្ថន័យ។

២. ក្រសួងពាក់ព័ន្ធគួរមានការសម្របសម្រួល និងការឆ្លើយតបជាលក្ខណៈប្រព័ន្ធ និងដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាស្វ័យប្រវត្តិ (Automated and online technology) ដើម្បីកាត់បន្ថយភាពស្មុគ្រស្មាញនៃកិច្ចការ រដ្ឋបាលដូចជាការចុះឈ្មោះអង្គការ/សមាគម ការចុះឈ្មោះចូលរួមក្នុងវេទិកាពាក់ព័ន្ធផ្សេងៗ ការដាក់ជូន របាយការណ៍ ការជូនដំណឹងមួយចំនួន ដូចជាការជូនដំណឹងអំពីការផ្លាស់ប្តូរថ្នាក់ដឹកនាំ ការផ្លាស់ប្តូរទីស្នាក់ការ ឬបើកការិយាល័យសាខា ការផ្លាស់ប្តូរ ឬបង្កើតគណនីប្រតិបត្តិការធនាគារ និងការចុះអនុស្សរណៈឡើងវិញសម្រាប់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស និងការជូនដំណឹងសំខាន់ៗផ្សេងៗពីអង្គការសង្គមស៊ីវិលជាដើម។

៣. ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធនានាគួររៀបចំឲ្យមានការផ្សព្វផ្សាយ អប់រំ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ បទប្បញ្ញត្តិនានា ក៏ដូចជានីតិវិធីអនុវត្តន៍ ព្រមទាំងមានជនបង្គោល ឬមន្ត្រី និងឯកសារ/មធ្យោបាយទំនាក់ទំនងច្បាស់លាស់ សម្រាប់ពេលមានបញ្ហាពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធ។

៤. ស្នើសុំរាជរដ្ឋាភិបាលគួរនិរាករណ៍នូវប្រកាសអន្តរក្រសួងលេខ ១៧០ ប្រក.អន្តរក្រ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ិនធ័រណេត ព្រោះខ្លឹមសារនៃប្រកាសនេះមានលក្ខណៈទូលាយ និងអាចមានផលវិបាកជាអវិជ្ជមានក្នុងការអនុវត្តន៍។

៥. រាជរដ្ឋាភិបាល ជាពិសេសក្រសួង សេដ្ឋកិច្ចហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារគួរបន្តផ្តល់ការលើកទឹកចិត្តដល់អង្គការ ឬសមាគម ឬសហជីពទាំងឡាយណាដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធ ហើយមិនទាន់បំពេញកាតព្វកិច្ច អនុលោមច្បាប់ស្តីពីសារពើពន្ធ ឲ្យបានត្រឹមត្រូវ ដោយលើកលែងការផាកពិន័យ និងទោសទណ្ឌនានា។ ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា គួរតែត្រូវបានពន្យាពេលអនុវត្តចំពោះអង្គការ សមាគម មិនមែនរដ្ឋាភិបាល ឬសហជីព ហើយរាជរដ្ឋា ភិបាលគួរគាំទ្រ និងសម្របសម្រួលអង្គការ សមាគម ឬសហជីព ឲ្យមានសមត្ថភាព លទ្ធភាព និងធនធានសមស្របសម្រាប់រៀបចំប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុផ្ទៃក្នុង និងអ្នកពាក់ព័ន្ធ រួមទាំងម្ចាស់មូលនិធិ។

៦. រាជរដ្ឋាភិបាល ជាពិសេស **គ.ជ.អ.ប** ជម្រុញ និងលើកទឹកចិត្តដល់សាមីក្រសួងពាក់ព័ន្ធជាងដប់ (១០) ធ្វើការពន្លឿនការផ្ទេរមុខងារ និងសេវាសំខាន់ៗ ជាពិសេស សេវារដ្ឋបាលជាង៦០០ ប្រភេទដែលបានកំណត់រួចរាល់របស់ខ្លួន ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបំណាច់ឆ្នាំ២០២០។ បើអាចសូមពង្រឹង និងពង្រីក បរិមាណ និងគុណភាពនៃ **ច្រកចេញចូលតែមួយ** (One Window Service) ដល់គ្រប់ស្រុក/ខណ្ឌ ខេត្ត/រាជធានី និងសាមីក្រសួងទាំងឡាយ ក្នុងបំណាច់ឆ្នាំ២០២១ខាងមុខ។

៧. យើងខ្ញុំសូមជម្រុញ និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាល បង្កើនប្រសិទ្ធភាព ប្រសិទ្ធផល និងភាពស៊ីសង្វាក់គ្នាក្នុងកំណែទម្រង់ទាំងបីគឺ កំណែទម្រង់**រដ្ឋបាលសាធារណៈ** កំណែទម្រង់**ហិរញ្ញវត្ថុសាធារណៈ** និង កំណែទម្រង់**វិមជ្ឈការ និងវិសហមជ្ឈការ** ។ កំណែទម្រង់**រដ្ឋបាលសាធារណៈ** គឺសំដៅធ្វើយ៉ាងណាអនុវត្តលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ និងក្រោមជាតិឲ្យបានពេញលេញ បង្កើនប្រាក់បៀវត្ស និងប្រឆាំងអំពើពុករលួយ ព្រមទាំងធានាថាមន្ត្រីរាជការជា**អ្នកបំរើប្រជាពលរដ្ឋដោយឯករាជ្យ មានគុណភាព និងគុណធម៌**។ សាលាសុចរិតភាពត្រូវមានធនធានមនុស្ស ថវិកា និងវិសាលភាពគ្រប់គ្រាន់សំរាប់បណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល និងអ្នកពាក់ព័ន្ធ គ្រប់លំដាប់ថ្នាក់ពីភាពជាអ្នកដឹកនាំ គោលការណ៍អភិបាលកិច្ចល្អ ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

៨. យើងខ្ញុំសូមស្នើដល់រាជរដ្ឋាភិបាល ពន្លឿនការអនុវត្ត**អភិក្រមភាពជាដៃគូពហុភាគី(រដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន)** តាមរយៈការពង្រឹង និងពង្រីកគុណភាពយន្តការដែលមានស្រាប់ដូចជាក្រុមការងារបច្ចេកទេសចម្រុះគ្រប់ភាគី (TWG) និងគណៈកម្មាធិការគ្រប់គ្រង (PSC) គណនេយ្យភាពសង្គម ឲ្យមានទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។ **អភិក្រមភាពជាដៃគូពហុភាគី** គួរមានឯកសារមគ្គុទេស និងត្រូវបានអនុវត្តសាកល្បង និងពង្រីកជាបន្តបន្ទាប់នៅក្នុងកម្រិតខេត្ត និងស្រុក ដែលវិស័យអាទិភាពទាំងឡាយអាចចូលរួមក្នុងគ្រប់ដំណាក់កាលអភិវឌ្ឍ និងការសម្រេចចិត្ត។ លើសពីនេះ យើងខ្ញុំកត់សម្គាល់ថាមានច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនត្រូវបានតាក់តែងឡើង និងចូលជាធរមាន ហើយមានប្រយោជន៍ក្រៃលែងសម្រាប់ប្រជាពលរដ្ឋ។ យើងខ្ញុំសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធបង្កើន**ការផ្សព្វផ្សាយ និងអប់រំ** មិនត្រឹមតែដល់មន្ត្រីរាជការ ប៉ុន្តែប្រជាពលរដ្ឋ និងសាធារណៈជនឲ្យបានទូលំទូលាយ និងកាន់តែប្រសើរជាងនេះ។

៩. ស្នើដល់រាជរដ្ឋាភិបាលបង្កើតគោលនយោបាយលើកទឹកចិត្ត អង្គការ ឬសមាគម ដើម្បីបង្កលក្ខណៈងាយស្រួលដើម្បីឲ្យ វិស័យនេះអាចបន្តរួមចំណែកបំពេញបេសកកម្មរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ គោលនយោបាយទាំងនោះរួមមានៈ ក) ការវិភាជនូវថវិកាជាតិមួយចំនួនឲ្យដល់អង្គការសង្គម ស៊ីវិល, ខ) ការផ្តល់ការអនុគ្រោះនិងរួចពីកាតព្វកិច្ចសារពើពន្ធមួយចំនួន ដូចជាពន្ធលើប្រាក់ចំណូលដែលកើតចេញពីអាជីវកម្ម ឬផលរបរខ្នាតតូច និងមធ្យម របស់ពួកគេ ក្នុងគោលដៅសុទ្ធសាធរបស់ពួកគេ និងមិនបែងចែកភាគលាភគ្នា។ គ) បង្កើតច្បាប់ស្តីពីសហគ្រាសសង្គម (Social Enterprise) ឬគោលនយោបាយនៃការធ្វើជំនួញដោយបញ្ចូលនូវគោលការណ៍សាជីវកម្មទទួលខុសត្រូវកិច្ចការសង្គម (Corporate Social Responsibility)។

១០. រាជរដ្ឋាភិបាល ជាពិសេសក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គួរផ្តល់ការសម្របសម្រួលឲ្យបានកាន់តែច្រើនជាងមុន ក្នុងការផ្តល់ទិដ្ឋាការដល់ជនបរទេសដែលបម្រើការងារឲ្យអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា។ បន្ថែម ពីនេះទៅទៀត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក៏គួរជួយសម្រួលឲ្យ

ដំណើរការនៃការចុះ និងបន្តអនុស្សារណៈនៃការ យោគយល់ជាមួយអង្គការបរទេស ឲ្យអាចដំណើរការទៅបាន ដោយរលូនប្រកបទៅដោយបរិយាកាសយោគយល់ និងភាពជាដៃគូ។

១១. យើងខ្ញុំសូមលើកទឹកចិត្តដល់រដ្ឋាភិបាល**ពន្លឿនការអនុមត័ច្បាប់សិទ្ធទទួលព័ត៌មាន** និងអនុវត្តវាឲ្យមានប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ តបទៅតាមសារាចរថ្មីៗរបស់រាជរដ្ឋាភិបាល ស្តីអំពីការរៀបចំឲ្យមានការពិគ្រោះយោបល់ក្នុងដំណើរការតាក់តែងក្របខណ្ឌគោលនយោបាយ និងច្បាប់នានា យើងខ្ញុំស្នើសុំយ៉ាងទទូចឲ្យមានការអនុវត្តតាមសារាចរនេះឲ្យបានពេញលេញ ដោយមាន**ការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធឲ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយអត្ថន័យ**។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលត្រូវពង្រឹងឡើងវិញនូវសេរីភាពនៃសារព័ត៌មាន ដោយបង្កលក្ខណៈឲ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរបស់សង្គមស៊ីវិលអាចដំណើរការឡើងវិញបាន។

១២. យើងខ្ញុំស្នើដល់រាជរដ្ឋាភិបាលមេត្តាពិនិត្យ និងធ្វើវិសោធនកម្មលើ ច្បាប់ស្តីសមាគម និងអង្គការមិនមែនរដ្ឋាភបាល ជាពិសេសមាត្រា៨, មាត្រា៩, មាត្រា ២៤ និងមាត្រាមួយចំនួនទៀត ដើម្បីធានានូវសិទ្ធសេរីភាព និងការពារការបកស្រាយដែលអាចបំពានដល់សេរីភាពនៃការបញ្ចេញមតិ និងការបង្កើត ព្រមទាំងការធ្វើសកម្មភាពរបស់អង្គការ សមាគម។ ក្រៅពីនេះ រាជរដ្ឋាភិបាលគួរផ្តោតសំខាន់ឲ្យមានសេចក្តីពន្យល់អត្ថន័យ និងនិយមន័យមាត្រាមួយចំនួននៃ "ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល" ឱ្យកាន់តែច្បាស់ដើម្បីជៀសវាងការយល់ផ្សេងគ្នា និងបកស្រាយខុសៗគ្នា។

**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីស្នេហា!**

ឆ្លៀតឱកាសនេះ ខ្ញុំបាទតាងនាមឲ្យអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា អង្គការជាសមាជិកទាំងអស់ និងអង្គការសង្គមស៊ីវិលជាដៃគូផ្សេងៗ សូមបញ្ជាក់យ៉ាងមុតមាំថា សង្គមស៊ីវិលប្តេជ្ញាចិត្តនឹងដើរតួនាទីយ៉ាងសំខាន់ដូចខាងក្រោមៈ

១) **ការឆ្លើយតបនឹងគ្រោះមហន្តរាយធម្មជាតិ និងជំងឺរាត្បាតនានា** តាមរយៈការផ្តល់ជំនួយមនុស្សធម៌ យុទ្ធនាការ និងការអប់រំបង្ការ និងការព្យាបាល។ តួយ៉ាងការចូលរួមឆ្លើយតបនឹងគ្រោះមហន្តរាយយ៉ាងមានប្រសិទ្ធភាព, និង ការកាត់បន្ថយការរីករាលដាលមេរោគអេដស៍ឲ្យនៅក្នុងកម្រិតទាបបំផុត, ២) **ការចូលរួមពង្រឹងគុណភាពសេវានានា** ជាពិសេសសេវាអប់រំ សុខាភិបាល និងអភិវឌ្ឍន៍ជនបទរួមទាំងអនាម័យទូទៅ និងគមនាគមន៍ជនបទ, ៣) **ការលើកកម្ពស់ប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស** តាមរយៈការអប់រំផ្សព្វផ្សាយ ការពង្រឹងភាពអង់អាច និងពលរដ្ឋសកម្មចូលរួមក្នុងការសមរេច ព្រមទាំងអនុវត្តន៍ក្របខណ្ឌគណនេយ្យភាពសង្គម, ៤) **ការអភិវឌ្ឍន៍ធនធានមនុស្ស**ដល់ប្រជាពលរដ្ឋជាក្រុមគោលដៅផង អាជ្ញាធរ និងមន្ត្រីរដ្ឋភិបាលផង ៥) ការចូល

រួមកំណែទម្រង់ **និងការអភិវឌ្ឍន៍នូវគោលនយោបាយ/ច្បាប់**នានារបស់រាជរដ្ឋាភិបាល, ៦) **ការលើកជីវភាពរស់នៅ និងមុខរបរ,** ៧) **ការអភិរក្សធនធានធម្មជាតិ និង** ៨) **ការតស៊ូមតិ និងការសន្ទនាលើគោលនយោបាយពាក់ព័ន្ធ** ជាដើម ។ល។

ដើម្បីឲ្យការចូលរួមរបស់អង្គការសង្គមស៊ីវិលបានពេញលេញ គឺយើងខ្ញុំត្រូវការ**បរិយាកាសបំពេញការងារដ៏ល្អមួយ** ជាពិសេសបរិយាកាសនយោបាយដែលមានភាពជាដៃគូស្មើភាពគ្នា ក្របខណ្ឌច្បាប់ដ៏អំណោយផល និងការអនុវត្តច្បាប់ដែលមានលក្ខណៈលើកទឹកចិត្ត និងការពារ និងស្តង់ដារតែមួយ។

មុននឹងបញ្ចប់ ខ្ញុំបាទសូមសម្តែងការកោតសរសើរ និងថ្លែងអំណរគុណចំពោះ សម្តេចក្រឡាហោម **ស ខេង** ថ្នាក់ដឹកនាំ និងសហការីទាំងអស់របស់ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធនានា ក្នុងការលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាប័ន្នសំរាប់ការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព និងប្រជាធិបតេយ្យ។

សូមគោរពជូនពរ **សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** ឲ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងសុខសប្បាយក្លាយជាសេដ្ឋីទាំងអស់គ្នា នៅក្នុងឱកាសចូលឆ្នាំថ្មីនេះផងដែរ។

**សូមអរគុណ!**